**VilaWeb** គឺជាសាព័ត៌មានអេឡិចត្រូនិចនាំមុខគេនៅប្រទេសកាតាឡែន។អត្ថបទនេះគឺជាចំណែកមួយរបស់ផ្នែកពិសេសរបស់សេចក្តីប្រកាសអធិបតេយ្យភាពដែលមានច្រើនភាសា.

សភារបស់កាតាឡែនអនុម័តសេចក្តីប្រកាសអធិបតេយ្យភាព

បុព្វកថា

ឆ្លងកាត់ប្រវត្តិសាស្រ្តដ៏យូរលង់ប្រជាជនកាតាឡែនបានបង្ហាញឆន្ទៈរួមក្នុងការគ្រប់គ្រងប្រទេសដោយខ្លួនឯងដោយមានទិសដៅជម្រុញការអភិវឌ្ឍរបស់ពួកគេ សុខមាលភាពនិងនាំមកនូវឱកាសស្មើៗគ្នាសម្រាប់ពលរដ្ឋគ្រប់រូបស្របពេលជាមួយការលើក
កម្ពស់វប្បធម៌ និងអត្តសញ្ញាណរួមមួយ។
ស្វ័យភាពគ្រប់គ្រងរបស់កាតាឡែនត្រូវបានបង្កើតឡើង នូវសិទ្ធិជាប្រវត្តិសាស្រ្តរបស់ប្រជាជន ក្នុងគ្រឹះស្ថានអប់រំបុរាណ និងប្រពៃណីស្របច្បាប់របស់កាតាឡែន។សភាកាតាឡែនមានដើមកំណើតតាំងពីមជ្ឈឹមសម័យក្នុង Assemblees de Pau i Treva  និង Cort Comtal។

នៅសតវត្សរទី១៤ Diputació del General, រឺដែលគេស្គាល់ថា Generalitat, ទទួលបានស្វ័យភាពកម្រិតខ្ពស់រហូត
ក្លាយជារដ្ឋាភិបាលប្រទេសកាតាឡែននៅក្នុងសតវត្សរទី១៦និង១៧។ការបែកបាក់ទីក្រុងបាសេឡូណាក្នុងឆ្នាំ១៧១៤ពេលមានសង្គ្រាមផលប្រយោជន៍ដែលនាំទៅរកការគ្រប់គ្រងរបស់អេស្ប៉ាញ Felip V ជាមួយរាជក្រឹត្យ Nova Planta បានលុបចោល
សិទ្ធិរបស់កាតាឡែន និងស្ថាប័នអប់រំ នូវស្វ័យភាពគ្រប់គ្រង។
ប្រវត្តិសាស្រ្តដូចនេះមានការទាក់ទងទៅនឹងផ្នែកផ្សេងៗច្រើនដទៃទៀត មានដូចជាភាសា វប្បធម៌ សង្គម និងសេដ្ឋកិច្ចជាមួយនឹង ការតាំងចិត្ត ដើម្បីលើកកម្ពស់ និងការប្រឹងប្រែងដើម្បីទទួលបានការទទួលស្គាល់គ្នាទៅវិញទៅមក។

ពេញមួយសតវត្សរទី២០ឆន្ទៈដែលចង់បានស្វ័យគ្រប់គ្រងរបស់ប្រជាជនកាតាឡែនមានការជក់ជាប់ជាដរាប។ការបង្កើតឡើងនូវ Mancomunitat de Catalunya នៅក្នុងឆ្នាំ១៩១៤ដែលជាជំហានដំបូងក្នុងការទទួលយកមកវិញនូវស្វ័យភាពប៉ុន្តែត្រូវច្រាន
ចោលជាសាធារណៈដោយលោក Primo de Rivera ។ក្នុងឆ្នាំ១៩៣១ដោយការប្រកាសជាសារណៈដោយសាធារណៈរដ្ឋ
អេស្ប៉ាញទី២រដ្ឋាភិបាលកាតាឡែនត្រូវបានបង្កើតឡើងដែលគេស្គាល់ថាមានឈ្មោះGeneralitat de Catalunya និងទទួលយកនូវឋានៈស្វ័យភាព។
រដ្ឋាភិបាលនេះត្រូវបានគេបដិសេធចោលម្តងទៀតនៅឆ្នាំ១៩៣៩ដោយឧត្តមសេនីយ៍ Franco ដែលបានបង្កើតរដ្ឋផ្តាច់ការដែល
បញ្ចប់នៅឆ្នាំ១៩៧៥។រដ្ឋអំណាចនេះត្រូវទទួលរងការប្រឆាំងពីប្រជាជននិងរដ្ឋាភិបាលកាតាឡែន។ព្រឹត្តិការណ៍សំខាន់ជាប្រវត្តិសាស្រ្តក្នុងការប្រយុទ្ធប្រឆាំងដើម្បីសេរីភាពក្នុងឆ្នាំ១៩៧១ដោយ Assemblea de Catalunya មុននឹងបង្កើត Generalitat ជាថ្មីឡើងវិញក្នុង
លក្ខណៈបណ្តោះសអាសន្នរហូតដល់ការត្រឡប់វិញរបស់ប្រធានាធិបតីនិរទេសឆ្នាំ១៩៧៩។ក្នុងសម័យអន្តរកាលឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យនេះនិងក្នុងបរិបទប្រព័ន្ធស្វ័យភាពក្នុងតំបន់ដូចដែលមានចែងក្នុងរដ្ឋធម្មនុញអេស្ប៉ាញឆ្នាំ១៩៧៨ប្រជាជនកាតាឡែនបានទទួលយកតាមរយៈការធ្វើប្រជាមតិមួយនាឆ្នាំ១៩៧៩ស្តីពីឋានៈស្វ័យភាពហើយនៅឆ្នាំ១៩៨០ការបោះឆ្នោតជ្រើសរើសសភាលើកទីមួយរបស់ប្រទេសកាតាឡែនត្រូវបានរៀបចំឡើង។
ក្នុងកំឡុពេលប៉ុន្មានឆ្នាំចុងក្រោយនេះការពង្រឹងលទ្ធិប្រជាធិបតេយ្យកម្លាំងនយោបាយនិងសង្គមភាគច្រើនរបស់កាតាឡែនបានជម្រុញដល់ការផ្លាស់ប្តូរប្រពន្ធ័តុលាការ និងនយោបាយ ដែលការប្រឹងប្រែងនាពេលថ្មីៗនេះ គឺជាដំណើរការកំណែទម្រង់ស្វ័យភាព ផ្តួចផ្តើមដោយសភានាឆ្នាំ២០០៥។ការលំបាកនិងឧបសគ្គពីស្ថាប័ននានារបស់អេស្ប៉ាញពិសេសតុលាការជាន់ខ្ពស់ទាក់ទងនឹងការជំនុំជំរះ ៣១/២០១០ជាការចរចារដាច់ខាតតាមរយៈការវិវឌ្ឍលទ្ធិប្រជាធិបតេយ្យស្របតាមបំណងរួមរបស់ប្រជាជនកាតាឡែន ហើយបានបង្កើតនូវមូលដ្ឋានសម្រាប់ការវិលត្រលប់ទៅរកស្វ័យភាពដូចដើមហើយសព្វថ្ងៃនេះគេឃើញមានក្នុងទិដ្ឋភាពនានាដូចជានយោបាយ តុលាការ ហិរញ្ញវត្ថុ សង្គម វប្បធម៌ និងភាសា។

ប្រជាជនការកាតាឡែនបាននឹងកំពុងប្រើប្រាស់គ្រប់មធ្យោបាយដូចដែលបានសម្តែងអោយឃើញនូវក្នុងឆន្ទៈរួមដើម្បីជំនះលើឧប-សគ្គនានាបង្ករឡើងដោយរដ្ឋាភិបាលអេស្ប៉ាញ។ ការធ្វើបាតុកម្មជាសាធារណៈនៅថ្ងៃទី១០ខែកក្កដាឆ្នាំ២០១០ក្រោមពាក្យស្លោក យើងជាប្រទេសមួយនិងការធ្វើបាតុកម្មជាសាធារណៈនៅថ្ងៃទី១១ខែកញ្ញាឆ្នាំ២០១២ក្រោមពាក្យស្លោកកាតាឡែនគឺជារដ្ឋថ្មីមួយ
របស់អឺរ៉ុប ទាំងនេះគឺជាការសម្តែងពីការប្រឆាំងចំពោះប្រការដែលមិនទទួលយកការសម្រេចចិត្តរបស់ប្រជាជនកាតាឡែន។
នៅថ្ងៃ២០ខែកញ្ញាឆ្នាំ២០១២និងអនុលោមតាមកិច្ចព្រមព្រៀង 742/IX សភាកាតាឡែនបញ្ជាក់ពីតម្រូវការដែលប្រជាជនកាតាឡែនត្រូវសម្រេចជោគវាសនារួមរបស់ពួកគេ ដោយសេរី និងតាមបែបប្រជាធិបតេយ្យ តាររយៈការធ្វើប្រជាមតិមួយ។ ឆន្ទៈនេះមានលក្ខណៈច្បាស់ និងសម្តែងចេញជាឯកច្ឆ័នជាមួយនឹងលទ្ធផលបោះឆ្នោតសភាកាតាឡែន កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១២ កាលពីពេលថ្មីៗនេះ។

ដើម្បីសម្រេចនូវបុព្វហេតុនេះសភាកាតាឡែនដែលបានបើកកិច្ចប្រជុំពេញអង្គនីតិកាលទី១០និងអនុលោមតាមឆន្ទៈរបស់ប្រជាពលរដ្ឋកាតាឡែន តាមរយៈការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ បានដាក់ចេញនូវកម្មវិធីនយោបាយដូចខាងក្រោម ៖

ការប្រកាសអធិបតេយ្យភាព និងសិទ្ធិសម្រេចលើរដ្ឋកាតាឡែន ក្នុងនាមជាប្រទេសមួយ

ឆ្លងតាមឆន្ទៈប្រជាធិបតេយ្យក្នុងសម្លេងភាគច្រើននៃប្រជាជនកាតាឡែនសភាកាតាឡែនដាក់ចេញនូវដំណើរការដើម្បីលើកម្ពស់សិទ្ធិប្រជាពលរដ្ឋតាកាឡែន ដើម្បីសម្រេចជារួមលើអនាគតនយោបាយ ដូចជា៖

អធិបតេយ្យភាព កាតាឡែនជានិតិរដ្ឋប្រជាធិបតេយ្យ ដែលមានអធិបតេយ្យភាពនយោបាយ និងស្របច្បាប់់។

និតិរដ្ឋប្រជាធិបតេយ្យ ដំណើរការអនុវត្តសិទ្ធិ ដើម្បីសម្រេចឆន្ទៈ នឹងត្រូវមានលក្ខណៈប្រជាធិបតេយ្យ ជាពិសេសមានការធានា និងការគោរពចំពោះមតិនានាដោយមានការពិភាក្សាដេញដោលក្នុងក្របខ័ណ្ឌសង្គមកាតាឡែន។ប្រការនេះធានាអោយមានការសម្តែងអំពីឆន្ទៈក្នុងសម្លេងភាគច្រើន ដែលជាកក្តាជារូបវ័ន្តអំពីសិទ្ធិសម្រេច។

តម្លាភាព   ការធានាដល់កត្តាចាំបាច់ទាំងអស់ដើម្បីអោយប្រជាជនកាតាឡែនទាំងអស់និងសង្គមកាតាឡែនទាំងមូលទទួលបាន
នូវព័ត៌មាន និងចំណេះដឹងទាំងឡាយទាក់ទងនឹងសិទ្ធិដើម្បីសំរេចលើនីតិវិធី និងលើកកម្ពស់ការចូលរួមក្នុងនីតិវិធីនោះ។
ការពិភាក្សា   រដ្ឋការតាឡែននឹងចូលរួមក្នុងការពិភាក្សានិងការចរចាជមួយរដ្ឋាភិបាលអេស្ប៉ាញស្ថាប័ននានារបស់អឺរ៉ុបនិងជាមួយ
បណ្តាអង្គការអន្តរជាតិ។
សាមគ្គីភាពសង្គម   សាមគ្គីភាពសង្គមនិងសាមគ្គីភាពទឹកដីរបស់កាតាឡែននឹងត្រូវបានធានារួមជាមួយនឹងឆន្ទៈរបស់ប្រជាជន
កាតាឡែន ដូចដែលបានសម្តែងអោយឃើញយ៉ាងច្រើនសារក្នុងសង្គមកាតាឡែន ទាក់ទងនឹងការរក្សាឯកភាពជាតិ។
អឺរ៉ុបនីយកម្ម   គោលការណ៍ជាសារវ័ន្តរបស់សហគមអឺរ៉ុបនឹងត្រូវទទួលបានការការពារនិងលើកកំពស់ជាពិសេសសិទ្ធិជាមូលដ្ឋានរបស់ប្រជា
ពលរដ្ឋ លទ្ធិប្រជាធិបតេយ្យ ការប្តេជ្ញាចិត្តចំពោះសុខមាលភាពរបស់រដ្ឋ សាមគ្គីភាពជាមួយប្រទេសនានាក្នុងតំបន់អឺរ៉ុប និងចំពោះការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និង
វប្បធម៌។
នីត្យានុកូលភាព រាល់ក្របខណ្ឌនីតិកម្មនានា នឹងត្រូវបានប្រើប្រាស់ ដើម្បីលើកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការប្រើប្រាស់សិទ្ធិសម្រេច។
តួនាទីស្នូលរបស់សភា   សភាកាតាឡែនក្នុងនាមជាស្ថាប័នតំណាងអោយប្រជាពលរដ្ឋកាតាឡែនមានតួនាទីសំខាន់ក្នុងដំណើរ
ការនេះ ពោលគឺសភានឹងមានតួនាទីចាំបាច់ក្នុងការសម្រេច និងបញ្ជាក់ច្បាស់់នូវយន្តការ និងជាចលករសម្រាប់ដំណើរការ ដែលធានាដល់គោលាការណ៍នេះ។
កិច្ចសហការ   សភាកាតាឡែននិង Generalitat កាតាឡែនត្រូវធ្វើជាអ្នកចូលរួមយ៉ាងសកម្មក្នុងក្របខណ្ឌតំបន់ជាកម្លាំងស្នូលផ្នែក
សមាសភាពនយោបាយសេដ្ឋកិច្ចនិងសង្គមជាអង្គការវប្បធម៌អង្គការស៊ីវិលរបស់ប្រទេសនិងត្រូវបញ្ជាក់ច្បាស់ពីយន្តការដែលនឹងធានាចំពោះគោលការណ៍នេះ។
សភាកាតាឡែនជម្រុញដល់ប្រជាពលរដ្ឋកាតាឡែនទាំងអស់ ដើម្បីដើរតួនាទីយ៉ាងសកម្មក្នុងដំណើរការប្រជាធិបតេយ្យ សំដៅឆ្ពោះទៅរកសិទ្ធិស្វ័យសម្រេច។

វិមានសភា, 22 មករា, 2013